# ផែនការយុទ្ធសាស្ត្រ
# សមាគមបណ្តាញកសិករ និងធម្មជាតិ
# ២០២៤-២០២៨

( ៣ ឆ្នាំរំកិល )



សមាគមបណ្តាញកសិករ និងធម្មជាតិ

Farmer and Nature Net Association

# មាតិកា

**បញ្ជីអក្សរកាត់** ........ iii
**អារម្ភកថា** ........ iv
**ផ្នែកទី១៖ ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រ** ........ 1
១.១. សេចក្តីផ្តើម ........ 1
១.២. ដំណើររៀបចំផែនការយុទ្ធសាស្ត្រ ........ 1
**ផ្នែកទី ២៖ ប្រវត្ត និងយុត្តិកម្ម** ........ 3
២.១. បរិបទកម្ពុជា ........ 3
២.១.១ ទិដ្ឋភាពទូទៅ ........ 3
២.១.២ ស្ថានភាពនយោបាយ ........ 3
២.១.៣ ក្របខ័ណ្ឌតំបន់ ........ 4
២.១.៤ បញ្ហាប្រឈមនៃការអភិវឌ្ឍន៍សំខាន់ៗ ........ 4
២.២. បរិបទនៃប្រតិបត្តិការ ........ 5
២.៣. អំពីសមាគមបណ្តាញកសិករ និងធម្មជាតិ ........ 7
២.៣.១ ការចូលរួមកន្លងមក ........ 7
២.៣.២ អត្ថប្រយោជន៍នៃកម្មវិធីរបស់សមាគមបណ្តាញកសិករ និងធម្មជាតិ ........ 9
២.៣.៣ ការចូលរួមនាពេលអនាគត ........ 10
ផ្នែកទី ៣៖ យុទ្ធសាស្ត្រអន្តរាគមន៍ ........ 12
៣.១. វត្ថុបំណងយុទ្ធសាស្ត្រ ........ 12
៣.១.១ បញ្ហាឆ្លងផ្នែក ........ 17
៣.២. សូចនាករ និងចំណុចដៅ ........ 18
៣.៣. អនិក្រម និងបណ្តាញនៃអន្តរាគមន៍ ........ 19
៣.៣.១ អភិក្រមយុទ្ធសាស្ត្រ ........ 19
៣.៣.២ បណ្តាញនៃអន្តរាគមន៍ ........ 21
៣.៤. ទ្វមិសាស្ត្រនៃប្រតិបត្តិការ ........ 21
៣.៥. ក្រុមគោលដៅ ........ 21
៣.៦. សម្ព័ន្ធភាពយុទ្ធសាស្ត្រ ........ 22
៣.៦.១ ភាពជាដៃគូនៃការអនុវត្តកម្មវិធី ........ 22
៣.៦.២ ភាពជាដៃគូក្នុងការធានាធនធាន ........ 23
៣.៧. ក្របខ័ណ្ឌពេលវេលា ........ 23

៣.៨. និរន្តរភាព ........ 23
៣.៨.១ និរន្តរភាពនៃកម្មវិធី ........ 23
៣.៨.២ និរន្តរភាពស្ថាប័ន ........ 24
**ផ្នែកទី ៤៖ ប្រភពធនធាន** ........ 24
៤.១. តម្រូវការធនធាន ........ 24
៤.២. ផែនការគៀងគរធនធាន ........ 26
**ផ្នែកទី ៥៖ ការគ្រប់គ្រង** ........ 26
៥.១. គោលបំណងស្ថាប័ន ........ 26
៥.២. ហានិភ័យ និងកត្តាសន្មត ........ 27
៥.២.១ ហានិភ័យពីខាងក្រៅ ........ 27
៥.២.២ ហានិភ័យផ្ទៃក្នុង ........ 28
៥.៣. យន្តការពិនិត្យឡើងវិញ ........ 28
៥.៤. រចនាសម្ព័ន្ធគ្រប់គ្រង ........ 29
**ឧបសម្ព័ន្ធ** ........ 31
ឧបសម្ព័ន្ធ ១៖ រចនាសម្ព័ន្ធនៃសមាគមបណ្ដាញកសិករនិងធម្មជាតិ ........ 31
ឧបសម្ព័ន្ធ ២៖ ខេត្តគោលដៅរបស់ ប.ក.ធ ........ 32
ឧបសម្ព័ន្ធ ៣៖ យុទ្ធសាស្ត្រ សូចនាករ និងចំណុចដៅ ២០២៤-២០២៨ ........ 33
ឧបសម្ព័ន្ធ ៤៖ តម្រូវការធនធានសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ២០២៤-២០២៨ ........ 40

# បញ្ជីអក្សរកាត់

| | |
|---|---|
| ប.ក.ធ | សមាគមបណ្តាញកសិករ និងធម្មជាតិ |
| AC | Agriculture Cooperative |
| AFA | Asian Farmers' Association for Sustainable Rural Development |
| CDP | Commune Development Plan |
| CIP | Commune Investment Program |
| DCA | DanChurchAid |
| EU | European Union |
| FNN | Farmer and Nature Net Association |
| IFAD | International Fund for Agricultural Development |
| PG | Producer Group |
| PME | Planning Monitoring and Evaluation |
| SWOT | Strengths Weakness Opportunity Threat |

# អារម្ភកថា

សមាគមបណ្តាញកសិករ និងធម្មជាតិ សម្រេចបានផែនការយុទ្ធសាស្រ្ត ២០២១-២០២៥ ដោយសហការជាមួយសមាជិកបណ្តាញកសិករ និងធម្មជាតិ និងអ្នកពាក់ព័ន្ធផ្សេងទៀត។ សមិទ្ធិផលដែលសម្រេចបានរួមមាន៖ ការបង្កើនសមត្ថភាព និងលទ្ធភាពផលិតកម្មកសិកម្មតាមបច្ចេកទេស Agroecology ជាពិសេសកសិកម្មសរីរាង្គ បង្កើនឱកាសទីផ្សារសម្រាប់សហគមន៍កសិកម្ម ពង្រឹងអភិបាលកិច្ចសហគមន៍កសិកម្ម ការលើកកម្ពស់គុណភាពផលិតផល ការពង្រឹងសមត្ថភាពគ្រូសហគមន៍កសិកម្មមន៍ និងការបង្កើនការស្វែងរកមូលនិធិសម្រាប់ការអភិវឌ្ឍន៍អាជីវកម្ម។ វិធានការកែលម្អផលិតកម្មកសិកម្ម គុណភាពផលិតផល និង ការឆ្លើយតបទៅនឹងតម្រូវការទីផ្សារ បានធ្វើឲ្យអាជីវកម្មរបស់សហគមន៍កសិកម្ម និងសមាជិកទទួលបានជោគជ័យបន្ថែមទៀត ហើយសហគមន៍កសិកម្មភាគច្រើនក៏កាន់តែសកម្ម ក្នុងការអភិវឌ្ឍន៍អាជីវកម្មរបស់ខ្លួន។ ម្យ៉ាងទៀត សមាគមបណ្តាញកសិករ និងធម្មជាតិបានរួមចំណែកក្នុងការសម្រេសគោលដៅអភិវឌ្ឍចីរភាព (SDGs) ទី១ លប់បំបាត់ភាពក្រីក្រ ទី១០ កាត់បន្ថយវិសមភាព ក៏ដូចជាយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ផងដែរ។

សម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ (២០២៤-២០២៨) សមាគមបណ្តាញកសិករ និងធម្មជាតិ ប្តេជ្ញាចិត្ត ដើម្បីការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១ លប់បំបាត់ភាពក្រីក្រ ទី១០ កាត់បន្ថយវិសមភាព និងយុទ្ធសាស្រ្តបញ្ចកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៧។ ក្នុងផែនការយុទ្ធសាស្រ្ត ២០២៤-២០២៨ សមាគមបណ្តាញកសិករ និងធម្មជាតិ នឹងបន្តសម្រេចគោលដៅយុទ្ធសាស្រ្ត ១) សមត្ថភាពរបស់កសិករ និងមេដឹកនាំ ទាក់ទងនឹងការផលិតមានការកើនឡើងប្រកបដោយគុណភាព និងសុវត្ថិភាព ២) ក្រុម សមាគមកសិករ ជួយខ្លួនឯង និងសហគមន៍កសិកម្ម មានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាកម្មដល់សមាជិកប្រកបដោយប្រសិទ្ធភាព ៣) ការទទួលបានទីផ្សាររបស់កសិករ ៤) ការទទួលបានដើមទុន/ធនធានហិរញ្ញវត្ថុ ៥) ការទទួលបាននូវបរិយាកាសគាំទ្រនានា និង ៦) សមាគមបណ្តាញកសិករ និងធម្មជាតិក្លាយជាស្ថាប័នមានសមត្ថភាព និង វិជ្ជាជីវៈខ្ពស់ ក្នុងការផ្តល់សេវាកម្មឱ្យសមាជិកប្រកបដោយប្រសិទ្ធភាព។

ផែនការយុទ្ធសាស្ត្រសមាគមបណ្ដាញកសិករ និងធម្មជាតិ ២០២៤-២០២៨ ត្រូវបាន រៀបចំឡើងដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាងសហគមន៍កសិកម្ម និងក្រុមការងារនៃសមាគមបណ្ដាញកសិករ និងធម្មជាតិ សម្រាប់ការអភិវឌ្ឍន៍សហគមន៍កសិកម្ម ដើម្បីសម្រេចចក្ខុវិស័យរបស់ខ្លួន។

សមាគមបណ្ដាញកសិករ និងធម្មជាតិ សូមសម្ដែង និង កោតសរសើរចំពោះ សមាជិកក្រុមប្រឹក្សាភិបាល ក្រុមការងារ និងបុគ្គលិក នៃសមាគមបណ្ដាញកសិករ និងធម្មជាតិ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨។ សមាគមបណ្ដាញកសិករ និងធម្មជាតិ សូមអំពាវនាវការគាំទ្រ និងកិច្ចសហការបន្តក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រ ២០២៤ -២០២៥ សម្រាប់អនាគតសហគមន៍កសិកម្ម និងកសិករ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០២៤

ជ-សមាគមបណ្ដាញកសិករ និង ធម្មជាតិ

នាយកប្រតិបត្តិ

**ប៉ាន សុភាព**

## ផ្នែកទី១៖ ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រ

### ១.១. សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា មានទីតាំងនៅអាស៊ីអាគ្នេយ៍ដីគោក ភាគខាងត្បូងនៃឥណ្ឌូចិន និងមានប្រជាជនសរុប ១៥.៦ លាននាក់ (ជំរឿន ២០១៩) ស្រី ៥១.៣១% និងអត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំ ១.៤%។ គ្រួសារកសិកម្ម មានចំនួន ២.០៣៨.០០០ គ្រួសារ មានគ្រួសារជាម្ចាស់កម្មសិទ្ធិដីកសិកម្ម ១.៩៩១.០០០ គ្រួសារនិងគ្រួសារជួលដីពីគ្រួសារដទៃ ៩៨.០០០ គ្រួសារ។ ចំណែកគ្រួសារដែលមានតែដីជុំវិញបរិវេណលំនៅដ្ឋាន ២៧៨.០០០ គ្រួសារ។

ដោយឡែក សមាគនបណ្តាញកសិករនិងធម្មមជាតិ(ប.ក.ធ) ដែលជា អង្គការក្នុងស្រុកមិនស្វែងរកប្រាក់ចំណេញ បានបង្កើតឡើងនៅឆ្នាំ ២០០៣ និងបានចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃថ្ងៃទី១០ ខែ មីនា ឆ្នាំ ២០០៦។ ប.ក.ធ តំណាងឱ្យបណ្តាញអង្គការកសិករតាមមូលដ្ឋានដែលធ្វើសកម្មភាពជាធត្រមួយតំណាងឱ្យនិងបម្រើដល់ផលប្រយោជន៍ របស់សមាគមខ្លួនឯង សហគមន៍កសិកម្មម និង ផ្តល់ជំនួយបច្ចេកទេសសម្រាប់កសាងសមត្ថភាព។ ជាទូទៅសមាជិកភាគច្រើននៃប.ក.ធជាកសិករមានមុខរបរបន្ទាប់បន្សំនិងក្រីក្ររស់នៅតាមសហាគមន៏ជនបទ។ បច្ចុប្បន្ននប.ក.ធមានសមាជិក ៤៦,១៧៦នាក់ (ស្រី៣១,០០៩) មកពី១៦ខេត្តគោលដៅ ៥៦ស្រុក ២១៤ ឃុំ ៨០៤ ភូមិ និង ៨០២ សមាគមសន្សំប្រាក់។ ក្រៅពីនេះ មានសហាគមន៍ម៉ាស៊ីនកិនស្រូវដែលជាសមាជិក របស់ ប.ក.ធ នៅថ្នាក់ស្រុក ក្រុមផលិតស្រូវសរីរាង្គ ក្រុមផលិតបន្លែ ក្រុមចិញ្ចឹមមាន់។ ប.ក.ធ នៅថ្នាក់ជាតិ ដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសមាជិកជាប់ឆ្នោតតំណាងឲ្យកសិករចំនួន ១៨ រូបមកពី ១៥ ខេត្តគោលដៅ។ សមាគមបណ្តាញកសិករ និងធម្មជាតិ បានសម្របសម្រួល ផលិតផលរបស់សហាគមន៍កសិកម្ម ទៅកាន់ទីផ្សារ។

នេះជាស្នាដៃដ៏ធំធេង របស់ ប.ក.ធ និងសហាគមន៍កសិកម្មដែលជាសមាជិក ក្នុងការអនុវត្តន៍ផែនការ និងបេសកកម្មរបស់ខ្លួន។ ដើម្បីបន្តការអភិវឌ្ឍន៍សហាគមន៍កសិកម្មប្រកបដោយនិរន្តរភាព និងឆ្លើយតបទៅនឹងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ នាពេលអនាគត ប.ក.ធ នឹងពិនិត្យឡើងវិញ នូវសកម្មភាព យុទ្ធសាស្ត្រ វិធីសាស្ត្របំពេញការងាររបស់ខ្លួន។

### ១.២. ដំណើររៀបចំផែនការយុទ្ធសាស្ត្រ

ប.ក.ធ មានបណ្តាញកសិករតាំង ពីថ្នាក់ស្រុក ខេត្ត រហូតដល់ថ្នាក់ជាតិ។ ដើម្បីដំណើរការសម្របសម្រួលការរៀបចំភែនការយុទ្ធសាស្ត្រឆ្លើយតនឹងត្រូវការរបស់សហាគមន៍កសិកម្ម និងនិងអ្នកប្រើប្រាស់ក្នុង និងក្រៅស្រុក ប.ក.ធ បានបង្កើតក្រុមការងារបច្ចេកទេសរៀបចំផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ ដែលមានសមាសភាព ដូចជា នាយកប្រតិបត្តិ ប្រធានកម្មវិធី ប្រធាន

គម្រោងនិងទីប្រឹក្សារបស់ ប.ក.ធ ហើយដឹកនាំដោយ លោក ប៉ាន សុភាព នាយកប្រតិបត្តិ ប.ក.ធ។ ជាដំបូង ប.ក.ធ ចុះរៀបចំប្រជុំបណ្ដាញថ្នាក់ខេត្ត ដោយមានការចូលរួមពីតំណាងសហគមន៍កសិកម្ម ដែលជាសមាជិករបស់ ប.ក.ធ ដើម្បីសិក្សាថាតើ សហគមន៍កសិកម្មស្ថិតក្នុងស្ថានភាពបែបណា? ហេតុអ្វីបានជាមានស្ថានភាពបែបហ្នឹង? តើសហគមន៍កសិកម្មត្រូវការឬចង់បានអ្វីទៀតនៅពេលណា? បន្ទាប់មក ប.ក.ធ កោះប្រជុំបុគ្គលិក ដើម្បីវិភាគស្ថានភាពទាំងក្នុង និងខាងក្រៅរបស់ប.ក.ធ តាមរយៈ ការវិភាកស្វត (SWOT)។ បន្ទាប់មកទៀត ប.ក.ធ បាន ធ្វើសិក្ខាសាលារយៈពេលពីរថ្ងៃនៅក្រុងស្ទឹងសែនខេត្តកពង់ធំ ដែលមានការចូលរួមពី សមាជិកក្រុមប្រឹក្សាភិបាល ប.ក.ធ ដើម្បីលើកយុទ្ធសាស្រ្តឆ្ពោះទៅសម្រេចចក្ខុវិស័យរបស់ ប.ក.ធ។ ប្រមូលធាតុចូលទាំងត្រូវបានក្រុមការងាររៀបចំផែនការយុទ្ធសាស្រ្ត យកមកចងក្រងជាផែនការយុទ្ធសាស្រ្ត ២០២១-២០២៥ ហើយអនុមតិដោយក្រុមប្រឹក្សាភិបាល ដើម្បីឲ្យប.ក.ធ អនុវត្ត។

រូបភាពទី ១៖ អង្គពិគ្រោះយោបល់ និងផ្ដល់ធាតុចូលសម្រាប់ផែនការយុទ្ធសាស្រ្ត ២០២១-២០២៥



## ផ្នែកទី ២៖ ប្រវត្ត និងយុត្តិកម្ម

### ២.១. បរិបទកម្ពុជា

#### ២.១.១ ទិដ្ឋភាពទូទៅ

ព្រះរាជាណាចក្រកម្ពុជា មានទីតាំងនៅអាស៊ីអាគ្នេយ៍ដីគោក ភាគខាងត្បូងនៃឥណ្ឌូចិន និងមានប្រជាជនសរុប ១៥.៦ លាននាក់ (ជំរឿន ២០១៩) ស្រី ៥១.៣១% និងអត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំ ១.៤%។ គ្រួសារកសិកម្ម មានចំនួន ២.០៣៨.០០០ គ្រួសារ មានគ្រួសារជាម្ចាស់កម្មសិទ្ធិដីកសិកម្ម ១.៩៩១.០០០ គ្រួសារនិងគ្រួសារជួលដីពីគ្រួសារដទៃ ៩៨.០០០ គ្រួសារ។ ចំណែកគ្រួសារដែលមានតែដីជុំវិញបរិវេណលំនៅដ្ឋាន ២៧៨.០០០ គ្រួសារ។

កម្ពុជាបានងើបចេញពីជម្លោះដ៏អូសបន្លាយនាពេលថ្មីៗនេះ ហើយប្រឈមមុខនឹងបញ្ហាប្រឈមជាច្រើនក្នុងការបន្តការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច នយោបាយ និងបរិស្ថាន និងការលើកកម្ពស់សិទ្ធិកសិករ។ វឌ្ឍនភាពមានភាពមិនស្មើគ្នារវាងទីក្រុង និងជនបទ ភាពក្រីក្រត្រូវបានកាត់បន្ថយជាបណ្ដើរៗ ការគ្រប់គ្រងដីកសិកម្មប្រកបដោយនិរន្តរភាពនៅតែជាបញ្ហាប្រឈម ខណៈដែលបច្ចេកទេស និងគោលនយោបាយនៅមានកម្រិត។ សកលភាវូបនីយកម្ម និងវិបត្តិសេដ្ឋកិច្ចទូទាំងពិភពលោក (ដូចជា កូវីដ-១៩ ផ្ដាសាយបក្សី) ផ្ដល់នូវបញ្ហាប្រឈមបន្ថែមទៀតដល់សេដ្ឋកិច្ច។

សកម្មភាពសេដ្ឋកិច្ចសំខាន់គឺកសិកម្ម។ ប្រជាជនកម្ពុជាមួយភាគធំបានចូលរួមក្នុងសកម្មភាពវិស័យបឋមដូចជា ការដាំដុះ (ស្រូវ បន្លែ ឈើហូបផ្លែ...) ការចិញ្ចឹមសត្វ ការនេសាទ និងការកែច្នៃផលិតផលកសិកម្ម ដើម្បីទទួលបានចំណូលខ្ពស់។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP 2014-2018) បង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាប្ដេជ្ញាកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សុខុមាលភាពទូទៅរបស់ប្រជាជនកម្ពុជាទាំងអស់។ យុទ្ធសាស្ត្រចតុកោណដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់ការណែនាំដើម្បីសម្រេចបានគោលបំណងនេះ។ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ក្រុមផលិត និងអង្គការសង្គមស៊ីវិលត្រូវបានស្វាគមន៍ និងកោតសរសើរចំពោះការរួមចំណែករបស់ពួកគេក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា។

#### ២.១.២ ស្ថានភាពនយោបាយ

សង្គ្រាមស៊ីវិលបានបញ្ចប់ទាំងស្រុងក្នុងឆ្នាំ ១៩៩៩។ ស្ថិរភាពនយោបាយ និងសន្តិភាពបានបានគ្រប់ដណ្ដប់ទូទាំងប្រទេស។ ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ កម្ពុជាបានក្លាយជាលទ្ធិប្រជាធិបតេយ្យពហុបក្សនៅឆ្នាំ១៩៩៣។ ចាប់តាំងពីពេលនោះមក ប្រទេសកម្ពុជាបាន

រៀបចំការបោះឆ្នោតជាតិចំនួនប្រាំមួយ និងការបោះឆ្នោតឃុំសង្កាត់ចំនួនបី តាមរបៀបប្រជាធិបតេយ្យ ដោយមានការចូលរួមយ៉ាងសកម្មពីសង្គមស៊ីវិល។ លទ្ធផលនៃការបោះឆ្នោតជាតិលើកក្នុងឆ្នាំ២០១៨ គណៈបក្សប្រជាជនកាន់កាប់អស្សនៈទាំងអស់នៅក្នុងរដ្ឋសភាជាតិ។ បញ្ហាចំបងគឺការរក្សាស្ថិរភាពនយោបាយ និងសន្តិភាពសម្រាប់ការអភិវឌ្ឍប្រទេស និងលទ្ធិប្រជាធិបតេយ្យក្នុងគ្រាដែលគ្មានបក្សប្រឆាំង។ ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យត្រូវបានលើកកម្ពស់តាមរយៈកំណែទម្រង់គោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការ ហើយត្រូវបានពង្រឹងដោយសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត។

ស្ថានភាពសិទ្ធិមនុស្សមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ ប៉ុន្តែសង្គមកម្ពុជានៅតែប្រឈមមុខនឹងបញ្ហាមួយចំនួនក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ និងក្នុងការលើកកម្ពស់សិទ្ធិកសិករខ្នាតតូចដែលមានចែងនៅអង្គការសហប្រជាជាតិ (UNDROP)។

បញ្ហាចំនួនបីដែលគួរយកចិត្តទុកដាក់ជាពិសេសគឺ៖ i) តម្រូវការសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃនីតិរដ្ឋ និងកាត់បន្ថយកម្រិតនៃអំពើពុករលួយ ii) កង្វះការអនុវត្តច្បាប់ដីធ្លី និងទឹកសម្រាប់កសិកម្ម ធ្វើឱ្យប៉ះពាល់ដល់ផលិតកម្មកសិកម្ម របស់សមាជិកសហគមន៍ និង សន្តិសុខស្បៀង iii) កង្វះបទប្បញ្ញត្តិ និងហេដ្ឋារចនាសម្ព័ន្ធសមស្របសម្រាប់វិស័យកសិកម្ម ធ្វើឱ្យកសិករប្រឈមនឹងកង្វះទីផ្សារ ខ្វះទុនផលិត និងជម្លោះក្នុងការធ្វើជំនួញកសិកម្ម។

### ២.១.៣ ក្របខ័ណ្ឌតំបន់

កម្ពុជាជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងអង្គការពាណិជ្ជកម្មពិភពលោក ក៏ដូចជាកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌនៃមហាអនុតំបន់មេគង្គ ដែលផ្តល់ឱកាសដ៏ល្អសម្រាប់ការជំរុញ និងធ្វើពិពិធកម្មកសិកម្ម និងសេដ្ឋកិច្ចពីកំណើនមូលដ្ឋានតូចចង្អៀត។ ទោះយ៉ាងណាក៏ដោយ ឧបសគ្គដែលកម្ពុជាប្រឈមរួមមាន: សមត្ថភាពនៃការផ្គត់ផ្គង់ ធនធានមនុស្ស និងសមត្ថភាពស្ថាប័ន។ កត្តាទាំងអស់នេះ បានរារាំងប្រទេសកម្ពុជាពីការទទួលបានអត្ថប្រយោជន៍ពេញលេញពីសមាជិកភាពរបស់ខ្លួននៅក្នុងស្ថាប័នអន្តរជាតិទាំងនេះ។

### ២.១.៤ បញ្ហាប្រឈមនៃការអភិវឌ្ឍន៍សំខាន់ៗ

កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលពឹងផ្អែកលើជំនួយ ឬកម្ចីបរទេស ដែលមានចំណាត់ថ្នាក់សន្ទស្សន៍សកលភាពក្រីក្រពហុសមាសភាគ (MPI) របស់កម្ពុជាបានធ្លាក់ចុះពី០.១៦៨ ក្នុងឆ្នាំ២០១៤ មកត្រឹម ០.០៧០ ក្នុងឆ្នាំ ២០២១/២០២២ ហើយអត្រានៃភាពក្រីក្របានធ្លាក់ចុះពី៣៦.៧

ភាគរយមកត្រឹម ១៦.៦ ភាគរយ និងភាពងាយរងគ្រោះទៅនឹងភាពក្រីក្រ ២០.៥% (របាយការណ៍អង្គការទិន្នន័យអំពីការអភិវឌ្ឍ)។

ទោះបីជាប្រទេសកម្ពុជាបានរីកចម្រើនក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះក្នុងការកាត់បន្ថយភាពក្រីក្រ ការកែលម្អលទ្ធភាពទទួលបានការបណ្ដុះបណ្ដាល ការលើកកម្ពស់សមភាពយេនឌ័រ ការកាត់បន្ថយបុព្វហេតុដែលទាក់ទងនឹងចំណាកស្រុក និងការជំរុញកំណើនសេដ្ឋកិច្ចក៏ដោយ ក៏នៅមានច្រើនទៀតដែលត្រូវធ្វើ។ វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវការកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត និងឆន្ទៈនយោបាយដ៏រឹងមាំ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់លើកទី៤ នៅទូទាំងប្រទេស។ គោលនយោបាយអភិវឌ្ឍន៍ក្រីក្រ កំណែទម្រង់ប្រព័ន្ធតុលាការ និងការគ្រប់គ្រងដីធ្លីកសិកម្ម និងធនធានធម្មជាតិប្រកបដោយសមធម៌ គឺមានភាពពាក់ព័ន្ធដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ចីរភាព (SDG) របស់កម្ពុជា។

ផ្នែកសំខាន់ៗដែលវិស័យកសិកម្មព្រួយបារម្ភគឺ៖ ការចូលរួមរបស់យុវជននៅមានកម្រិត វិសមភាពយេនឌ័រ ការបង្កើតយន្តការដោះស្រាយទំនាស់ និងការអនុវត្តបទប្បញ្ញត្តិមិនទាន់បានល្អ មិនមានច្បាប់ស្ដីពីកិច្ចសន្យាកសិកម្ម មុខងារប្រជាធិបតេយ្យនៅមានកម្រិតនៅក្នុងករណីខ្លះ កង្វះលទ្ធភាពទទួលបានការអប់រំបច្ចេកទេសកសិកម្មអេកូឡូស៊ី លទ្ធភាពទទួលបានសេវាសុខភាពប្រកបដោយគុណភាពនៅមានកម្រិត ការរីករាលដាលជំងឺឆ្លង(កូវីដ-១៩) កង្វះប្រព័ន្ធទឹកស្រោចស្រពដំណាំ កង្វះលទ្ធភាពទទួលបានទីផ្សារសម្រាប់ផលិតផលក្នុងស្រុក និង ភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ ដូចជា គ្រោះរាំងស្ងួត និងទឹកជំនន់ ជាដើម។

## ២.២. បរិបទនៃប្រតិបត្តិការ

កម្ពុជាមានសហគមន៍មូលដ្ឋានរឹងមាំជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើន ផ្នែកឯកជន និង រដ្ឋាភិបាល ពួកគាត់ត្រូវបានអញ្ជើញដោយរដ្ឋាភិបាល ដើម្បីចូលរួមក្នុងកិច្ចប្រជុំ SDGs សម្រាប់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ អង្គការក្រៅរដ្ឋាភិបាលភាគច្រើនផ្ដោតលើការងារអភិវឌ្ឍន៍តាមវិស័យ ដូចជាវិមជ្ឈការ និងលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការតស៊ូមតិ ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ការការពារបរិស្ថាន និងផ្សេងៗទៀត។ អង្គការសង្គមស៊ីវិលដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឱ្យសមាជិកសភាអនុម័តច្បាប់ថ្មី ដើម្បីផលប្រយោជន៍របស់ប្រជាពលរដ្ឋ ស្របតាមស្មារតីរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ និងឧបករណ៍ច្បាប់ផ្សេងទៀត និងធានាថាច្បាប់ដែលមានស្រាប់ត្រូវបានអនុវត្តប្រកបដោយអត្ថន័យ។ ជាងនេះទៅទៀត ពួកគាត់ក៏លើកកម្ពស់ និងស្វែងរកមតិគាំទ្រ ការគោរព ការការពារ និងការបំពេញសិទ្ធិរបស់ប្រជាពលរដ្ឋផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ពួកគាត់នៅតែខ្សោយខាងសមត្ថភាព និងធនធានហិរញ្ញវត្ថុ។

ទីភ្នាក់ងារអន្តរជាតិ និងអង្គការម្ចាស់ជំនួយទ្វេភាគី ក៏គាំទ្រដល់ការអភិវឌ្ឍន៍សង្គមស៊ីវិលផងដែរ។ នៅក្នុងជំនួយអន្តរជាតិ ការចូលរួមរបស់សង្គមស៊ីវិលគឺអាចទទួលយកបាននៅក្នុងសកម្មភាពទាំងអស់ រួមទាំងសិទ្ធិមនុស្ស ការស្វែងរកមតិគាំទ្រ ការអភិវឌ្ឍន៍សង្គម ការអភិវឌ្ឍន៍សេដ្ឋកិច្ច ការរើសអើងយេនឌ័រ និងផ្សេងៗទៀត។ ទាំងនេះត្រូវបានធ្វើក្នុងពេលដំណាលគ្នាជាមួយរដ្ឋាភិបាល ដើម្បីកែលម្អអភិបាលកិច្ច និងលើកកម្ពស់គណនេយ្យភាព ក្នុងការកាត់បន្ថយភាពក្រីក្រ។ កម្ពុជាក៏បានទទួលជំនួយបច្ចេកទេសយ៉ាងសំខាន់ពីតួអង្គទ្វេភាគី និងពហុភាគីតាំងពីឆ្នាំ១៩៩៣មកដែរ។ ប្រទេសម្ចាស់ជំនួយទ្វេភាគីឈានមុខគេរបស់កម្ពុជារួមមាន ជប៉ុន សហរដ្ឋអាមេរិក អូស្ត្រាលី ចិន បារាំង អាល្លឺម៉ង់ ចក្រភពអង់គ្លេស និងស្វីស។ ទីភ្នាក់ងារផ្តល់ជំនួយពហុភាគីឈានមុខគេរួមមានអង្គការសហប្រជាជាតិ ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី សហភាពអឺរ៉ុប IFAD និង ILO ។

បន្ទាប់ពីការបំផ្លិចបំផ្លាញដោយសង្គ្រាម និងជម្លោះ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋាភិបាលដ៏ទូលំទូលាយ ចាប់ពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិត្រូវបានបង្កើតឡើង។ ប្រទេសកម្ពុជាគឺជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញាអន្តរជាតិ ដែលបង្កើតជាផ្នែកនៃក្របខ័ណ្ឌទាំងមូលសម្រាប់សិទ្ធិរបស់ប្រជាពលរដ្ឋរបស់ខ្លួន។ កម្ពុជាកំពុងអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០១៩-២០២៣ របស់ខ្លួន ជាមួយនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលផ្តោតលើការលើកកម្ពស់អភិបាលកិច្ចល្អជាមួយនឹងវិស័យអាទិភាពចំនួនបួនៈ i)-ការលើកកម្ពស់វិស័យកសិកម្ម ii) ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត; iii) ការអភិវឌ្ឍន៍វិស័យឯកជន និងការបង្កើតការងារ និង iv) ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស។ យុទ្ធសាស្ត្រទាំងនេះផ្តល់ឱកាសមួយក្នុងការប្រមូលផ្តុំមិនត្រឹមតែតួអង្គជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីសម្រេចបាន គោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDGs) ផងដែរ។

ទោះជាយ៉ាងនេះក្តី កម្ពុជានៅប្រឈមខាងសមត្ថភាព និងធនធានហិរញ្ញវត្ថុ ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការបំពេញនូវកម្រិតជីវភាពអប្បបរមារបស់ប្រជាជនកម្ពុជា ទាក់ទងនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិដទៃទៀត ព្រមទាំងច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយ។ ដោយសារធនធានមានកម្រិត សេវារបស់រដ្ឋាភិបាលមិនត្រូវបានចែកចាយស្មើៗគ្នាទូទាំងប្រទេសទេ។ តំបន់ដាច់ស្រយាលនៅជនបទត្រូវបានផ្តល់សេវាតិច ហើយសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ (CCs) នៅមានកម្រឹត ហើយពួកគេខ្វះថវិកា។

គ្រួសារក្រីក្រមួយចំនួននៅក្នុងសហគមន៍ជួបនឹងសន្តិសុខស្បៀង និង ប្រាក់ចំណូលសម្រាប់តម្រូវការមូលដ្ឋានរបស់ពួកគេ។ កសិករភាគច្រើនកាន់កាប់តែដីតូចៗប៉ុណ្ណោះ ហើយខ្វះលទ្ធភាព

ទទួលបានឥណទានខ្នាតតូច និងចំណេះដឹងអំពីបច្ចេកទេសកសិកម្មសមស្រប និងការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងលទ្ធភាពទទួលបានប្រព័ន្ធធារាសាស្ត្រ។ កសិករខ្លះត្រូវបង្ខំចិត្តលក់ដីរបស់ខ្លួនក្នុងករណីសង្គ្រោះបន្ទាន់។ ដើម្បីបំពេញបន្ថែមប្រាក់ចំណូលតិចតួចរបស់ពួកគាត់ កសិករជាច្រើនពឹងផ្អែកលើការធ្វើចំណាកស្រុកតាមរដូវទៅកាន់តំបន់ទីក្រុង ឬនៅក្រៅប្រទេស ហើយពួកគាត់ត្រូវចាប់យកការងារដែលមានប្រាក់ខែទាប និងប្រឈមអសុវត្ថិភាពនៅចម្ការ។

មានកត្តាជាច្រើន (ដូចជា កសិករភាគច្រើននៅប្រើថ្នាំពុលកសិកម្ម ជីគីមី ការកាប់ព្រៃឈើខុសច្បាប់...) រួមចំណែកដល់ការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ប្រព័ន្ធកសិកម្មបែបប្រពៃណីខ្មែរ ដូចជាដំណាំស្រូវពឹងផ្អែកលើទឹកភ្លៀង គឺងាយរងគ្រោះដោយសារគ្រោះរាំងស្ងួត ទឹកជំនន់ និង ឡើងកំដៅ (អៀលនីញ៉ូ) ដែលកើតឡើងញឹកញាប់។ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ជនបទ ដូចជាផ្លូវថ្នល់ និងបច្ចេកវិទ្យាថ្មីៗ ដូចជាទូរសព្ទឆ្លាតវៃ ផ្តល់ឱកាសថ្មីសម្រាប់ការចូលទៅកាន់ទីផ្សារទៅកាន់សហគមន៍ជនបទនៅមានកម្រិត ពោលគឺមិនក្លាយជា សហគមន៍ឌីជីថល។

ជីវិតសង្ឃឹមរស់នៃប្រជាជនកម្ពុជា ៦៩.៥៨ឆ្នាំ ប្រហាក់ប្រហែលបើធៀបនឹង ជីវិតសង្ឃឹមរស់សកល (១៩២ ប្រទេស) គឺ ៧១.៥៨ឆ្នាំ (ទន្ន័យឆ្នាំ២០២១, The Global Economy)។ ប៉ុន្តែវាធ្លាក់ទាបជាងជីវិតសង្ឃឹមរស់កម្ពុជាគឺ ៧០.៦៩ឆ្នាំនៅឆ្នាំ២០១៩។ ទាំងនេះ អាចបណ្តាលមកពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុដែលធ្វើឲ្យប្រព័ន្ធសន្តិសុខស្បៀងនិងអាហារូបត្ថម្ភជួបការលំបាក និងកត្តារួមផ្សំផ្សេងទៀត ដូចជា សេវាសុខាភិបាល ការអប់រំផ្សព្វផ្សាយ ការយល់ដឹង និងប្រតិបត្តិរបស់ប្រជាជន។

## ២.៣. អំពីសមាគមបណ្តាញកសិករ និងធម្មជាតិ

### ២.៣.១ ការចូលរួមកន្លងមក

សមាគនបណ្តាញកសិករនិងធម្មជាតិ (ប.ក.ធ) ដែលជាអង្គការក្នុងស្រុក មិនស្វែងរក ប្រាក់ចំណេញ បានបង្កើតឡើងនៅឆ្នាំ ២០០៣ និងបានចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃថ្ងៃទី១០ ខែ មីនា ឆ្នាំ ២០០៦។ ប.ក.ធ តំណាងឱ្យបណ្តាញអង្គការកសិករតាមមូលដ្ឋានដែលធ្វើសកម្មភាពជាឆត្រមួយតំណាងឱ្យនិងបម្រើដល់ផលប្រយោជន៍ របស់សមាគមខ្លួនឯង សហគមន៍កសិកម្ម និង ផ្តល់ជំនួយបច្ចេកទេស សម្រាប់កសាងសមត្ថភាព។ ជាទូទៅសមាជិកភាគច្រើន នៃ ប.ក.ធ ជាកសិករមានមុខរបរបន្ទាប់បន្សំនិងក្រីក្ររស់នៅតាមសហគមន៍ជនបទ។ បច្ចុប្បន្ន ប.ក.ធ មានសមាជិក ៤៦,១៧៦នាក់ (ស្រី៣១,០០៩) មកពី១៦ខេត្តគោលដៅ ៥៦ស្រុក ២១៤ឃុំ ៨០៤ភូមិ និង ៨០២ សមាគមសន្សំប្រាក់ជួយខ្លួនឯង។ មូលធនសន្សំរបស់ សមាគមសន្សំប្រាក់

ជួយខ្លួន ឯងបានកើនឡើងដល់២៨,១៦២,១៩៩.០០ដុល្លាអាមេរិច ជាមួយគ្នានេះសមាគមសន្សំប្រាក់មានទុនទ្រទ្រង់ប្រមាណ ៨៣២,០០០.០០ដុល្លា អាមេរិចទុនបម្រុង ២២,៨២៣.០០ ដុល្លាអាមេរិច និងមូលធិនិសង្គម ៨០,០០៣.០០ ដុល្លាអាមេរិច។ ក្រៅពីនេះ មានសហគមន៍ម៉ាស៊ីនកិនស្រូវចំនួន ៦ ដែលជាសមាជិករបស់ ប.ក.ធ នៅថ្នាក់ស្រុក ដែលក្នុងនោះមាន៤ សហគមន៏ម៉ាស៊ីនកិនស្រូវ ធ្វើសកម្មភាពយ៉ាងសកម្ម។

ក្នុងឆ្នាំ ២០១៧ មានសហគមន៏កសិកម្មចំនួន៦២បានចុះឈ្មោះជាសមាជិករបស់ ប.ក.ធ ជាផ្លូវការ ដែលមានសមាជិក សរុប ១១,១៧៥ នាក់ (ស្រី ៦,៥៨៧ នាក់) និង ដំណើរការអាជីវកម្មផ្សេងៗគ្នាដូចជា ៣៦ ក្រុមផលិតស្រូវសរីរាង្គ ម៉ាស៊ីនកិនស្រូវ លក់ជីដាំដុះបន្លែចិញ្ចឹមសត្វផលិតចំណីសត្វនិងមួយក្រុមផលិតត្រី។ ប.ក.ធ នៅថ្នាក់ជាតិ ដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសមាជិកជាប់ឆ្នោតតំណាងឱ្យយកសិករចំនួន ១៥រូប មកពី១៥ខេត្តត គោលដៅ និង តំណាង ៤រូបទៀតមកពីបណ្តាញអ្នកជំនាញថ្នាក់ជាតិដូចជាបណ្តាញសន្សំប្រាក់និងឥណទាន បណ្តាញយុវជន និង បណ្តាញក្រុមផលិតស្រូវសរីរាង្គ។ នៅថ្នាក់តំបន់ ចាប់តាំងពីឆ្នាំ ២០០៨ មក ប.ក.ធ ជាសមាជិកមួយនៃ សមាគមកសិករអាស៊ីដើម្បីការអភិវឌ្ឍន៍ដោយចីរភាព។ ចាប់ពី២០១២ ដល់ ២០១៤ ប.ក.ធ បំពេញការងារជាប្រធានសមាគមកសិករអាស៊ី ដើម្បីការអភិវឌ្ឍន៍ដោយចីរភាព និង ជាគណៈកម្មាការគ្រប់គ្រងកសិកម្ម និង កម្មមវិធីសន្តិសុខស្បៀងពិភពលោកដែលមានតំណាងមកពីសង្គមស៊ីវិលអាស៊ី។ ក្នុងនាមជា សមាជិកគណៈកម្មាការគ្រប់គ្រងកសិកម្ម និង កម្មវិធី សន្តិសុខស្បៀងពិភពលោក ប.ក.ធ បាន ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាការគ្រប់គ្រងចំនួន២ដង នៅទីស្នាក់ការកណ្តាលធនាគារពិភពលោក នារដ្ឋវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិច។ ក្នុងភាពជាប្រធាននៃប.ក.ធត្រូវបានអញ្ជើញឱ្យយចូលរួម ៤ វេទិកាកសិករនៅទីស្នាក់ការកណ្តាល IFAD ទីក្រុងរ៉ូម ប្រទេសអ៊ីតាលី។

ក្នុងរយៈពេល ១៨ ឆ្នាំនៃការអនុវត្តគម្រោងទាំងនេះ ប.ក.ធ បានបង្កើតទំនាក់ទំនងការងារល្អជាមួយស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ រួមមាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ ក្រសួងធនធានទឹក អាជ្ញាធរមូលដ្ឋាន និងសមាជិកសហគមន៍។ ទាក់ទងនឹងកម្មវិធី ប.ក.ធ មានបទពិសោធន៍ (១) ការកាត់បន្ថយភាពក្រីក្រ សម្របសម្រួលសហគមន៍ក្រីក្រ ដូចជា រៀបចំក្រុមជួយខ្លួនឯងជាមួយទុនបង្វិល និងផ្តល់សិទ្ធិអំណាចដល់ពួកគេក្នុងការផ្តល់ប្រាក់កម្ចីខ្នាតតូចសម្រាប់បង្កើតប្រាក់ចំណូលដល់ សហគ្រាសខ្នាតតូច និង រៀបចំសហគមន៍កសិកម្ម ក្រុមផលិត និងកសាងសមត្ថភាពឱ្យពួកគេចូលរួមក្នុងទីផ្សាររួម ដើម្បីទទួលបានទីផ្សារថ្មី និងតម្លៃខ្ពស់សម្រាប់ផលិតផលរបស់ពួកគេ (២)

នៅតាមសហគមន៍កសិកម្ម ប.ក.ធ បានសម្របសម្រួលសហគមន៍ក្រីក្រក្នុងការរៀបចំ ផែនការអាជីវកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុ និងពង្រឹងសិទ្ធិអំណាចឱ្យពួកគេគ្រប់គ្រងអាជីវកម្មសហគមន៍របស់ពួកគេប្រកបដោយនិរន្តរភាព និង ផ្តល់ការយល់ដឹងអំពីច្បាប់សហគមន៍កសិកម្មសមត្ថភាពក្នុងការស្វែងមតិគាំទ្រ (៣) កសាងសម្ថភាពសហគមន៍កសិកម្ម ក្រុមផលិត និងក្រុមជួយខ្លួនឯងអំពី ជំនាញការគ្រប់គ្រង ដូចជា ការគ្រប់គ្រងស្ថាប័ន ការរក្សាទុកដាក់ឯកសារ ផែនការការអាជីវកម្ម ចំណេះដឹងហិរញ្ញវត្ថុ ការបិទបញ្ជី របាយការណ៍ហិរញ្ញវត្ថុ និងទំនាក់ទំនងទីផ្សារ ការស្វែងរកមតិគាំទ្រ ជំនាញបច្ចេកទេសកសិកម្ម រួមមាន ការដាំបន្លែ ការចិញ្ចឹមសត្វ ផលិតជីធម្មជាតិ កសិអេកូឡូស៊ី ។ល។ (៤) ក្នុងការកាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក) ការផ្តល់ការយល់ដឹងអំពីគ្រោះមហន្តរាយដោយសារការប្រែប្រួលអាកាសធាតុ (គ្រោះរាំងស្ងួត ទឹកជំនន់) ខ) ការលើកកម្ពស់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការផ្លាស់ប្តូរប្រព័ន្ធកសិកម្មបែបប្រពៃណី ដោយប្រើវិធីសាស្ត្រធន់នឹងគ្រោះរាំងស្ងួត ដូចជា កសិកម្មរួមបញ្ចូលគ្នា។ ការធ្វើកសិកម្មសរីរាង្គ ការធ្វើពិពិធកម្មដំណាំ និង គ) រួមចំណែកក្នុងការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព តាមរយៈការរក្សាគុណភាពដី។ ម្យ៉ាងទៀត ប.ក.ធ កសាងសមត្ថភាព សមាជិកសហគមន៍កសិកម្មក្នុងការកែឆ្នៃផលិតផលកសិកម្ម និងភ្ជាប់ទៅទៅផ្សារ។

ប.ក.ធ មានបទពិសោធន៍ក្នុងការប្រើប្រាស់យុទ្ធសាស្ត្រគម្រោងដែលសមស្រប និងមានប្រសិទ្ធភាព ដូចជា វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស RBA វិធីសាស្ត្រពង្រឹងអំណាច វិធីសាស្ត្រធ្វើការរួមគ្នា និងវិធីសាស្ត្រផ្អែកលើសហគមន៍ ដើម្បីផ្តល់លទ្ធភាពដល់សមាជិកសហគមន៍ក្រីក្រ និងក្រុមផលិសម្រាប់គ្រប់គ្រងសកម្មភាពរបស់ពួកគាត់ប្រកបដោយនិរន្តរភាព។ វិធីសាស្ត្រទាំងនេះ ក៏ត្រូវបានប្រើប្រាស់ ក្នុងការជំរុញការស្វែងរកមតិគ្រាំទ្រ ឬកិច្ចពិភាគ្សាគោលនយោបាយខ្សែច្រវាក់តម្លៃកសិកម្ម និងហិរញ្ញប្បទានសម្រាប់ផលិតកម្មកសិកម្មនៃសហគមនកសិកម្ម។

### ២.៣.២ អត្ថប្រយោជន៍នៃកម្មវិធីរបស់សមាគមបណ្តាញកសិករ និងធម្មជាតិ

ប.ក.ធ មានលក្ខណៈពិសេសក្នុងចំណោម NGO ក្នុងស្រុក ក្នុងប្រទេសកម្ពុជា ដោយសារចំណុចសំខាន់បី គឺៈ ១) បទពិសោធន៍ជាច្រើនក្នុងការបង្កើតសហគមន៍កសិកម្ម និងចងក្រងជាបណ្តាញថ្នាក់ស្រុក ខេត្ត និងថ្នាក់ជាតិ ដើម្បីស្វែងរកការគាំទ្រលើគោលនយោបាយកសិកម្ម និងទីផ្សារ។ ២) អភិវឌ្ឍសេដ្ឋកិច្ចសមាជិកសហគមន៍កសិកម្ម តារយៈការសាងសមត្ថភាពជំនាញគ្រប់គ្រង (management skills) និង បច្ចេកទេសកសិកម្មសរីរាង្គ ឬកសិអេកូឡូស៊ី កែឆ្នៃ (technical skills) និងគៀងគរធនធាន ដើម្បីការអភិវឌ្ឍអាជីវកម្មប្រកបដោយចីរភាព និង ៣)- បុគ្គលិកដែល

មានបទពិសោធន៍ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ព្រមទាំងមានទំនាក់ទំនងល្អជាមួយសហគមន៍ ស្ថាប័នរាជរដ្ឋាភិបាល និងអាជ្ញាធរ ដើម្បីជួយសម្រួលដល់ការ ដំណើរការពង្រឹងសិទ្ធិអំណាចសហគមន៍កសិកម្ម ឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

លើសពីនេះ ប.ក.ធ ជាសមាជិកបណ្តាញថ្នាក់ជាតិ ដូចជា, NGO Forum និង CamboDHRRA, នៅថ្នាក់អន្តរជាតិ រួមមាន AFA, LVC, AsiaDHRRA, ILC, ALiSEA។ គុណសម្បត្តិទាំងនេះនឹងត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រ ២០២១-២០២៥។

### ២.៣.៣ ការចូលរួមនាពេលអនាគត

នៅក្នុងសិក្ខាសាលាផែនការយុទ្ធសាស្ត្ររបស់ខ្លួនក្នុងខែមិនា ឆ្នាំ ២០២១ ក្រុមប្រឹក្សាភិបាល បុគ្គលិក ប.ក.ធ និង បានវិភាគបរិបទការងារ កម្មវិធី និងស្ថាប័ន ដោយផ្អែកលើបទពិសោធន៍ និងព័ត៌មានពីសហគមន៍កសិកម្ម បុគ្គលិករដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត ហើយបានកំណត់បញ្ហាប្រឈមសំខាន់ៗសម្រាប់កម្មវិធីថ្មីរបស់ខ្លួល បញ្ហាប្រឈមនៃការអភិវឌ្ឍន៍ចម្បង និងចំណុចខ្លាំង និងចំណុចខ្សោយនៃអង្គការរបស់ខ្លួន ក៏ដូចជាឱកាស និងកត្តាគំរាមកំហែង។

ខណៈពេល ប.ក.ធ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ដែលបានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងគុណភាពដីកសិកម្មដោយចីរភាព និង ការផ្តល់កសិកផល សរីរាង្គ (ដូចជា ស្រូវសរីរាង្គ ៤០០០ តោន និងបន្លែ ២០០០ តោន ក្នុងមួយឆ្នាំ)។

បញ្ហាប្រឈមសំខាន់ៗនៅតែត្រូវដោះស្រាយដោយ ប.ក.ធ រួមមាន (១) ការពង្រឹងសហគមន៍កសិកម្ម និងក្រុមផលិត តាមរយៈកម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងកសាងសមត្ថភាព ពិសេសការប្រជុំបណ្តាញឲ្យបានទៀងទាត់ (២) ការលើកកម្ពស់ជីវភាពរស់នៅ និងហេដ្ឋារចនាសម្ព័ន្ធផលិតកម្មកសិកម្មខ្នាតតូចសម្រាប់សហគមន៍កសិកម្ម (ដូចជា ផ្ទះសំណាញ់ ថាមពលព្រះអាទិត្យ ស្រះអណ្តូង...) (៣) ការកែលម្អការគ្រប់គ្រងគុណភាពដីតាមរយៈការអនុវត្តគោលការណ៍កសិអេកូឡូស៊ី និង (៤) បន្តស្វែងរកមតិគាំទ្រគោលនយោបាយខ្សែច្រវាក់តម្លៃកសិកម្ម (ដូចជា ផលិតកម្មឬធាតុចូលកសិកម្ម ទីផ្សារ កិច្ចសន្យាកសិកម្ម ឥណទាន ពិសេសការអភិវឌ្ឍខ្សែច្រវ៉ាក់តម្លៃ និងប្រព័ន្ធទីផ្សារកសិកម្មសម្រាប់អ្នកក្រីក្រ។

លើសពីនេះ ប.ក.ធ នឹងដោះស្រាយបញ្ហាប្រឈមថ្មីៗនៃការកាត់បន្ថយ និងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដែលបណ្តាលមកពីការឡើងកំដៅផែនដី ជាពិសេសគ្រោះរាំងស្ងួត និងទឹកជំនន់ដែលកើតឡើងញឹកញាប់ ហើយគំរាមកំហែងដល់ប្រព័ន្ធផលិតកសិកម្ម ក៏ដូចជា សន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជាទាំងមូល។ ប.ក.ធ នឹងពង្រីកសមាជិករបស់ខ្លួនក្នុងខេត្តដែលមានស្រាប់ និងខេត្តផ្សេងទៀត។ ទាំងនេះគឺជាផ្នែកដែលកា

វិនិយោគរបស់រាជរដ្ឋាភិបាល (NSDP 2014-2018) អាចត្រូវបានពង្រឹង និងគាំទ្រតាមរយៈការកសាងសមត្ថភាព និងបង្កើតភាពជាម្ចាស់ និងការគ្រប់គ្រងមូលដ្ឋានអាជីវកម្ម និងរចនាសម្ព័ន្ធសហគមន៍កសិកម្ម។

ប.ក.ធ នឹងបន្តប្រើប្រាស់វិធីសាស្ត្រកម្មវិធីយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពរបស់ខ្លួន ដែលត្រូវបានអនុវត្តដោយជោគជ័យ។ បណ្តាញដ៏រឹងមាំ និងទំនាក់ទំនងការងារល្អ ក៏ដូចជាការជឿទុកចិត្ត និងទំនុកចិត្តដែលបានបង្កើតឡើង អាចឱ្យ ប.ក.ធ បង្កើត និងពង្រីកតួនាទីរបស់ខ្លួន។ ការស្វែងរកមតិគាំទ្រ និងសម្ព័ន្ធភាពជាយុទ្ធសាស្ត្រនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត នឹងត្រូវបានពង្រឹងដើម្បីមានឥទ្ធិពលលើការអភិវឌ្ឍន៍គោលនយោបាយ និងការអនុវត្តច្បាប់ សំដៅកែលម្អអភិបាលកិច្ចល្អ គណនេយ្យភាពរបស់អាជ្ញាធរមានសមត្ថកិច្ច និងកាត់បន្ថយភាពក្រីក្រ។

សមាគមបណ្តាញកសិករ និងធម្មជាតិ ត្រូវបានណែនាំដោយៈ

**គុណតម្លៃៈ**

- សមគ្គីភាព និងសហការល្អ
- តម្កល់ផលប្រយោជន៍រួមរបស់កសិករជាធំ
- ប្រកាន់យកកសិកម្មសរីរាង្គ និងសុវត្ថភាព
- តម្លាភាព គណនេយ្យភាព និងសមធម៌។

**ទស្សនវិស័យៈ** *"ចង់ឃើញ កសិករកម្ពុជាមានជីវភាពធូរធារ រស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ និងមានភាពជាម្ចាស់ក្នុងការសម្រេចលើជោគវាសនាខ្លួនឯង"* ។

**បេសកម្មៈ**

- ចងក្រង/គៀរគរនិងរួមកម្លាំង(ជំរុញសង្គមជនបទមួយដែលមានសាមគ្គីភាព និងសហការគ្នាល្អ) ការរពារសិទ្ធ និងផលប្រយោជន៍រួម (កសិករ) ជាធំ។
- ជំរុញ និងលើកកម្ពស់កសិកម្មសរីរាង្គ និងតាមគោលការធម្មជាតិ
- ធានាឱ្យមានការសហការគ្នារវាងសហគមន៍ និងអង្គការស្ថាប័នពាក់ព័ន្ធក្នុង និងក្រៅប្រទេស។
- សម្រាបសម្រួលកសាងភាពជាដៃគូ ដើម្បីទទួលបាន សេវាកម្មហិរញ្ញវត្ថុ បច្ចេកទេស ធាតុចូលកសិកម្ម និងទីផ្សារ ។ល។.

- អភិវឌ្ឍសមត្ថភាពសមាជិកបណ្ដាញ ជាពិសេសអ្នកដឹកនាំសហគមន៍កសិកម្ម ក្រុមផលិត ក្រុមកែឆ្នៃ ក្រុមស្ត្រី ក្រុមយុវជន ។ល។ ដើម្បីក្លាយជាអ្នកតំណាង និងមេដឹកនាំល្អ។

## ផ្នែកទី ៣៖ យុទ្ធសាស្ត្រអន្តរាគមន៍

### ៣.១. វត្ថុបំណងយុទ្ធសាស្ត្រ

ប.ក.ធ កំណត់យុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋានរបស់កសិករ និងសហគមន៍កសិកម្ម។ យុទ្ធសាស្ត្រទាំងនេះ ឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់ជាតិ និងសកលលោក ដើម្បីកាត់បន្ថយភាពក្រីក្រ និងបង្កើនការគោរពសិទ្ធិមនុស្ស ក៏ដូចជាការផ្តល់ការយល់ដឹងអំពីកេរ្តិ៍ត្រូបរិស្ថាន និងការលើកកម្ពស់ការប្រើប្រាស់ធនធានក្នុងស្រុកសម្រាប់ផលិតកម្មកសិកម្មប្រកបដោយនិរន្តភាព។

ប.ក.ធ រួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព (SDGs) ដូចជាលុបបំបាត់ភាពក្រីក្រ (SDG 1) និង ភាពអត់ឃ្លាន (SDG 2) លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី (SDG 5) និងធានានិរន្តរភាពបរិស្ថាន (CMDG 7)។ គោលដៅរួមទាំងនេះនឹងត្រូវបានសម្រេចតាមរយៈគោលដៅយុទ្ធសាស្ត្រចំនួនប្រាំមួយ គឺ៖

**គោលដៅយុទ្ធសាស្ត្រ ១៖ សមត្ថភាពរបស់កសិករ និងមេដឹកនាំ ទាក់ទងនឹងការផលិតមានការកើនឡើងប្រកបដោយគុណភាព និងសុវត្ថិភាព។**

គោលដៅយុទ្ធសាស្ត្រនេះផ្តោតលើការលើកកម្ពស់សិទ្ធិអំណាចសហគមន៍កសិកម្ម និងកសិករក្នុងការកំណត់ និងដោះស្រាយបញ្ហា តម្រូវការ និងវត្ថុបំណងរបស់គាត់ ធានាការដឹកនាំការអភិវឌ្ឍន៍ គំនិតផ្តួចផ្តើម និងកម្មវិធីរបស់ពួកគាត់កាន់តែមាននិរន្តរភាពក្នុងរយៈពេលយូរ ជាជាងការពឹងផ្អែកលើការគាំទ្រពីខាងក្រៅ ជួយសហគមន៍កាន់តែមានភាពធន់ក្នុងការប្រឈមមុខនឹងបញ្ហា ភាពមិនជឿជាក់ និងការផ្លាស់ប្តូរ ជួយសហគមន៍ដែលខ្វះខាត និងជួបការលំបាក ទទួលបានសមត្ថភាពក្នុងការចូលរួមប្រកបដោយអត្ថន័យក្នុងការសម្រេចចិត្ត និង ទទួលបានធនធាន និងឱកាស និង គាំទ្រសិទ្ធិរបស់សហគមន៍ក្នុងការធ្វើជាតំណាង និងការគ្រប់គ្រងលើដំណើរការអភិវឌ្ឍន៍របស់ពួកគាត់ផ្ទាល់ ជាជាងតាមបញ្ជាពីខាងក្រៅ។

**យុទ្ធសាស្ត្រ៖**

១.១ អភិវឌ្ឍន៍សមត្ថភាពកសិករស្តីពីបច្ចេកទេសកសិកម្មតាមគោលការណ៍ធម្មជាតិ និង សុវត្ថិភាព កសិកធុរកិច្ច។

១.២ ជំរុញផលិតកម្មតាមគោលការណ៍ធម្មជាតិ និងសុវត្ថិភាព។

១.៣ កសាងសមត្ថភាពកសិករឱ្យក្លាយជាគ្រូបង្គោល ដើម្បីបណ្តុះបណ្តាលដល់កសិករ។

១.៤ សម្របសម្រួលជាមួយមន្ត្រីជំនាញកសិកម្ម ដើម្បីផ្តល់សេវាកម្មបច្ចេកទេសដល់ កសិករ។

១.៥ លើកកម្ពស់សមត្ថភាពកសិករជំរុញការផលិតធាតុចូលកសិកម្មដោយខ្លួនឯង (ពូជ ចំណីសត្វ ជី ថ្នាំកំចាត់សត្វល្អិត...)។

១.៦ រៀបចំឱ្យមានកន្លែងពិសោធន៍ និងកន្លែងរៀនសូត្រ(កសិករគំរូ សហាគមន៍គំរូ)។

១.៧ សម្របសម្រួលឱ្យមានសេវាបញ្ជាក់គុណភាពនិងផ្តល់វិញ្ញាបនបត្រទទួលស្គាល់ គុណភាព។

១.៨ លើកកម្ពស់កសិកម្មតាមបែបកេ្សត្របរិស្ថាន។

## គោលដៅយុទ្ធសាស្ត្រ ២៖ ក្រុម សមាគមកសិករ ជួយខ្លួនឯង និងសហាគមន៍កសិកម្ម មានសមត្ថភាព គ្រប់គ្រាន់ក្នុងការផ្តល់សេវាកម្មដល់សមាជិកប្រកបដោយប្រសិទ្ធភាព។

គោលដៅយុទ្ធសាស្ត្រនេះបង្កើតឡើង ដើម្បីជួយសហាគមន៍ឲ្យកំណត់អត្តសញ្ញាណ និង តម្រូវការរបស់អតិថិជនបានយ៉ាងត្រឹមត្រូវ។ ផ្តល់សេវាកម្មដែលបំពេញ ឬលើសពីតម្រូវការ និង ការរំពឹងទុកទាំងនោះ ដោយធានាបាននូវកម្រិតខ្ពស់នៃការពេញចិត្តរបស់អតិថិជន និង ដំណើរ ការក្នុងលក្ខណៈងាយស្រួល។ អង្គការកសិករអាចផ្តល់សេវាកម្មប្រកបដោយគុណភាពខ្ពស់ ដែល អាចទុកចិត្តបាន បន្តធ្វើបច្ចុប្បន្នភាពជាមួយនិន្នាការកសិកម្ម បច្ចេកវិទ្យា និងការអនុវត្តល្អបំផុត។ ជួយអង្គការកសិករឲ្យមានជំនាញជ្រៅជ្រះ ក្នុងការផ្តល់សេវាកម្ម ដែលអតិថិជនអាចជឿជាក់បាន ថា ពួកគេកំពុងទទួលបានសេវាកម្មពីអ្នកផ្តល់សេវាដែលមានចំណេះដឹង និងមានសមត្ថភាព។ ជា ទីបញ្ចប់ អង្គការកសិករអាចកសាងកេរ្តិ៍ឈ្មោះដ៏រឹងមាំសម្រាប់គុណភាព ភាពជឿជាក់ និងសេវា កម្មអតិថិជន។

### យុទ្ធសាស្ត្រ៖

២.១ ពង្រឹងសមត្ថភាពមេដឹកនាំសមាគមកសិករ សហាគមន៍កសិកម្មទាក់ទងនឹងការ គ្រប់គ្រង ភាពជាអ្នកដឹកនាំ បិទបញ្ជី ផែនការអាជីវកម្ម របាយការណ៍ និង ...។

២.២ លើកទឹកចិត្តឱ្យមានការជួបជុំឆ្លុះបញ្ចាំង ចែករំលែកព័ត៌មាន និងបិទបញ្ជីស្នាមទៀងទាត់។

២.៣ រៀបចំឱ្យមានកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ផ្តល់សេវាកម្មនិងធ្វើការឱ្យសហគមន៍កសិកម្ម។

២.៤ ជំរុញ និងលើកទឹកចិត្តយុវជន និងស្ត្រីឱ្យមានការចូលរួមក្នុងការដឹកនាំនិងគ្រប់គ្រងក្រុមជួយខ្លួនឯង សមាគម និងសហគមន៍កសិកម្ម។

២.៥ ភ្ជាប់សហគមន៍កសិកម្មទៅនឹងស្ថាប័ននានាដើម្បីទទួលការគាំទ្រ (ធនធានបច្ចេកទេស)។

២.៦ ពង្រឹងកិច្ចសហការការផ្ទេរចំណេះដឹងរវាងសហគមន៍ និងសហគមន៍។

២.៧ គាំទ្រកម្មវិធីអប់រំសមាជិកភាពរបស់សហគមន៍កសិកម្ម (ច្បាប់សហគមន៍កសិកម្ម)។

២.៨ ធ្វើការវាយតម្លៃលើភាពលូតលាស់ប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម។

២.៩ ការលើកទឹកចិត្តសមាជិកសហគមន៍ឱ្យបង្កើនទុនធ្វេរដង។ និង

២.១០ ជំរុញសហគមន៍កសិកម្មក្នុងការរៀបចំផែនការមុខរបររបស់ខ្លួនឆ្លើយតបនឹងតម្រូវការសមាជិក។

## គោលដៅយុទ្ធសាស្ត្រ ៣៖ ការទទួលបានទីផ្សាររបស់កសិករ

គោលដៅយុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីជួយអង្គការកសិករបង្កើតហេដ្ឋារចនាសម្ព័ន្ធទីផ្សារឌីជីថល ដែលអាចធ្វើអោយប្រសើរឡើងនូវលទ្ធភាពទទួលបានទីផ្សារ តាមរយៈពាណិជ្ជកម្មអេឡិចត្រូនិច និងការលក់តាមអ៊ីនធឺណិតផងដែរ។ ការបង្កើតប្រព័ន្ធព័ត៌មានទីផ្សារដែលផ្តល់ទិន្នន័យពេលវេលាជាក់ស្តែងអំពីតម្លៃ តម្រូវការ និងលក្ខខណ្ឌទីផ្សារផ្សេងទៀតអាចជួយអង្គការកសិករធ្វើការសម្រេចចិត្តអំពីការផលិត និងការលក់កាន់តែឆ្លើយតប។ ជួយអង្គការកសិកររៀបចំ ក្រុមផលិត ដែលអាចបង្កើនអំណាចចរចារួម និងលទ្ធភាពទទួលបានទីផ្សារ។ អង្គការកសិករទាំងនេះអាចប្រមូលផ្តុំការផ្គត់ផ្គង់ ចរចាតម្លៃប្រសើរជាងមុន និងភ្ជាប់ដោយផ្ទាល់ជាមួយអ្នកទិញខ្នាតធំ។ ពង្រឹងខ្សែច្រវាក់តម្លៃទាំងមូល (ពីផលិតកម្ម រហូតដល់ការកែច្នៃ និងចែកចាយ) ដែលអាចធ្វើអោយប្រសើរឡើងនូវលំហូរទំនិញ និងសេវាកម្មទៅកាន់ទីផ្សារ និងធ្វើឱ្យប្រសើរឡើងនូវបរិក្ខារដំណើរការ ការបង្កើតមជ្ឈមណ្ឌលប្រមូលផ្តុំ ឬការអភិវឌ្ឍន៍ការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ សម្របសម្រួលភាពជាដៃគូ និងកិច្ចសន្យារវាងអ្នកផលិត និងអ្នកទិញ (អ្នកលក់ដុំ ឬអ្នកលក់រាយ ពាណិជ្ជករ ឬឈ្មួញកណ្តាល) ដើម្បីបើកបណ្តាញទីផ្សារ

កាន់តែទូលំទូលាយ។ ជំរុញសកម្មភាពផ្សព្វផ្សាយដូចជាម៉ាកយីហោ វិញ្ញាបនបត្រគុណភាព និងទីផ្សារអាចជួយ អង្គការកសិករ/សហគមន៍ ក្នុងការបែងចែកផលិតផលរបស់ពួកគេ និងទទួលបានទីផ្សារថ្មី ឬតម្លៃខ្ពស់ជាង។ ម្យ៉ាងទៀត យើងជំរុញ ការស្វែងរកមតិគាំទ្រលើគោលនយោបាយ បទបញ្ញា និងការវិនិយោគរបស់រដ្ឋាភិបាលដែលអាចបង្កើតបរិយាកាសអំណោយផលសម្រាប់អង្គការកសិករ/សហគមន៍ក្នុងការចូលរួមក្នុងទីផ្សារ។ នេះរួមបញ្ចូលទាំងវិធានការ ដូចជា ការសម្របសម្រួលពាណិជ្ជកម្ម រចនាសម្ព័ន្ធពន្ធ និងការគាំទ្រហេដ្ឋារចនាសម្ព័ន្ធទីផ្សារ។

**យុទ្ធសាស្រ្ត៖**

៣.១ សម្របសម្រួលកសាងភាពជាដៃគូរជាមួយវិស័យឯកជន សាធារណៈ និងសហគមន៍កសិកម្ម។

៣.២ ពង្រឹងសមត្ថភាពកសិករទាក់ទងការគ្រប់គ្រងក្រោយពេលប្រមូលផល (ដឹកជញ្ជូន ការកែឆ្នៃ ស្តុកទុក រក្សាគុណភាព)។

៣.៣ ពង្រឹងម៉ាកយីហោផលិតផលរបស់សហគមន៍។

៣.៤ សម្របសម្រួលកន្លែងប្រមូលផ្តុំ និងចែកចាយផលិតផលកសិកម្ម។

៣.៥ បង្កើតផ្សារកសិករ និងធម្មជាតិ។

៣.៦ បង្កើតឱ្យមានការកែឆ្នៃ និងលក់ផលិតផលរបស់សហគមន៍។

៣.៧ ជំរុញបង្កើតទីផ្សារ Digital (E-markets)។

៣.៨ ជំរុញផលិតកម្មកសិកម្មតាមកិច្ចសន្យា ដល់សហគមន៍កសិកម្ម (contract farming)។

## គោលដៅយុទ្ធសាស្រ្ត ៤៖ ការទទួលបានដើមទុន/ធនធានហិរញ្ញវត្ថុ

នេះជាគោលដៅយុទ្ធសាស្រ្តមួយ ដែលជួយអង្គការកសិករ ឬសហគមន៍កសិកម្មទទួលបានធនធានគ្រប់គ្រាន់សម្រាប់ដំណើរការអាជីវកម្ម វិនិយោគលើទ្រព្យសកម្មចាំបាច់ បង្កើនសមត្ថភាពផលិតកម្មរបស់ខ្លួន និង បង្កើតផលិតផល សេវាកម្ម ឬបច្ចេកវិទ្យាថ្មីៗដែលអាចជួយឱ្យអាជីវកម្មរក្សាការប្រកួតប្រជែង និងចាប់យកឱកាសទីផ្សារថ្មី។ ម្យ៉ាងទៀត គោលដៅយុទ្ធសាស្រ្ត ចង់ឲ្យអង្គការកសិករ ឬសហគមន៍កសិកម្មមានទុនគ្រប់គ្រាន ដើម្បីទប់ទល់នឹងព្រឹត្តិការណ៍ដែលមិននឹកស្មានដល់ ដូចជាការធ្លាក់ចុះសេដ្ឋកិច្ច ការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ ឬការខូចខាតឧបករណ៍ និងចង់បង្ហាញពីស្ថិរភាពហិរញ្ញវត្ថុ និងសក្តានុពលនៃកំណើនអាជីវកម្ម ដែលអាចទាក់ទាញអ្នកវិនិយោគ អ្នកផ្តល់ប្រាក់កម្ចី និងដៃគូយុទ្ធសាស្រ្ត។

និងដើម្បីឲ្យអង្គការកសិករ ឬសហគមន៍កសិកម្មអាចអនុលោមតាមបទប្បញ្ញត្តិ ដែលអ្នកទិញ ឬឈ្មួញបានកំណត់ (ឧ. សហគមន៍កសិកម្មត្រូវដឹកស្រូវឲ្យ CACC ៣ ឡានសិន ទើប CACC ទំលាក់លុយឲ្យ)។

**យុទ្ធសាស្ត្រ៖**

៤.១ បង្កើតឥណទានសហគមន៍កសិកម្មថ្នាក់ជាតិ។

៤.២ គៀរគរធានធានផ្ទៃក្នុងសហគមន៍កសិកម្ម តាមរយៈសេវាកម្ម និងចំណូលពីសមាជិកភាព។

៤.៣ មូលនិធិ សប្បុរសធម៌ជាតិ និងអន្តរជាតិ។

៤.៥ សម្របសម្រួលកសាងភាពជាដៃគូជាមួយវិស័យឯកជន សាធារណៈ និងសហគមន៍កសិកម្ម។

## គោលដៅយុទ្ធសាស្ត្រ ៥៖ ការទទួលបាននូវបរិយាកាសគាំទ្រនានា

គោលដៅយុទ្ធសាស្ត្រនេះ គឺសម្របសម្រួលអង្គការកសិករ ឬសហគមន៍កសិកម្ម ដើម្បីស្វែងរកមិតិគាំទ្រដោយដាក់ចេញនូវគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ច្បាស់លាស់ ដូចជាការដាក់ចេញនូវកម្មវិធីនានា ការលើកទឹកចិត្ត (ឧ. ការធ្វើសមាហរណកម្មទៅក្នុងទីផ្សារក្នុងស្រុក និងតំបន់ ការប្រកួតប្រជែងស្មើភាព ការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងការការពារបរិស្ថាន ការលើកកម្ពស់ស្ថាប័ន និងកាត់បន្ថយនិតិវិធីរដ្ឋបាល...) និង ការបែងចែកធនធានប្រកបដោយសមធម៌ (ដូចជា ដី ទឹក ថាមពល ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធសហគមន៍) ដើម្បីលប់បំបាត់ឧបសគ្គនានា សម្រាប់សហគមន៍គ្រប់គ្រងប្រតិបត្តិការអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

**យុទ្ធសាស្ត្រ៖**

៥.១ បង្កើនកិច្ចសន្ទនាជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ(កសាងភាពជាដៃគូជាមួយវិស័យឯកជន សាធារណៈ និងសហគមន៍កសិកម្ម)។

៥.២ ដាក់បញ្ចូលផែនការសហគមន៍កសិកម្មទៅក្នុង CDP/CIP។

៥.៣ បង្កើនភាពជាដៃគូជាមួយរដ្ឋាភិបាល តាមរយៈកម្មវិធីអភិវឌ្ឍរបស់រដ្ឋាភិបាល។

៥.៤ ពង្រឹងបណ្តាញជាមួយស្ថាប័នពាក់ព័ន្ធខាងក្រៅ(ជាតិ និងអន្តរជាតិ)។

៥.៥ សិក្សាស្រាវជ្រាវ និងវាយតម្លៃគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ថ្នាក់ជាតិ តំបន់ និងសកល។

## គោលដៅយុទ្ធសាស្ត្រ ៦៖ ប.ក.ធ ក្លាយជាស្ថាប័នមានសមត្ថភាព និង វិជ្ជាជីវៈខ្ពស់ ក្នុងការផ្ដល់សេវាកម្មឱ្យសមាជិកប្រកបដោយប្រសិទ្ធភាព។

គោលដៅយុទ្ធសាស្ត្រនេះ នឹងផ្ដល់ឲ្យ ប.ក.ធ មានលទ្ធភាពទទួលបាននូវជំនាញ និង ចំណេះដឹងឯកទេសក្នុងវិស័យ ឬដែនជាក់លាក់របស់ខ្លួន សម្រាប់ដោះស្រាយបញ្ហាប្រឈម ធ្វើការសម្រេចចិត្តប្រកបដោយប្រាជ្ញាញាណ និងការបន្តធ្វើបច្ចុប្បន្នភាពជាមួយនឹងការអភិវឌ្ឍន៍ថ្មីៗ។ បង្កើត នីតិវិធី និងស្តង់ដារគុណភាពការងារ ដែលធានាបាននូវការផ្ដល់សេវាដែលអាចទុកចិត្តបានពីភាគីពាក់ព័ន្ធ និងជាប់លាប់។ ប.ក.ធ មានលទ្ធភាពប្រើប្រាស់ធនធាន (សម្ភារៈបរិក្ខារទំនើប បច្ចេកវិទ្យាទំនើប) និងធ្វើកិច្ចសហការជាមួយអ្នកពាក់ព័ន្ធបានយ៉ាងទូលំទូលាយ និងមានប្រសិទ្ធភាព។ ប.ក.ធ មានរចនាសម្ព័ន្ធល្អ មានយន្តការសម្រាប់គណនេយ្យភាព និងតម្លាភាព ដែលអាចបង្កើតទំនុកចិត្ត និង កេរ្តិ៍ឈ្មោះក្នុងចំណោមភាគីពាក់ព័ន្ធ។

### យុទ្ធសាស្ត្រ៖

៦.១ អភិវឌ្ឍន៍សមត្ថភាពបុគ្គលិក និងក្រុមប្រឹក្សាភិបាល។

៦.២ រៀបចំអោយមានបុគ្គលិកស្នូលទៅតាមជំនាញដែលឆ្លើយតបនឹងតម្រូវការជាក់ស្តែង។

៦.៣ រៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងអោយបានទៀងទាត់(ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ)។

៦.៤ រៀបចំ និងកែលម្អរឯកសារគោលនយោបាយ កិច្ចការរដ្ឋបាល ហិរញ្ញវត្ថុរបស់ស្ថាប័ន និងក្របខ័ណ្ឌការងារផ្សេងៗទៀត។

៦.៥ អភិវឌ្ឍន៍កម្មវិធីផ្សព្វផ្សាយ និងចែករំលែកចំណេះដឹង។

៦.៦ ពិនិត្យមើល និងកែសម្រួលរចនាសម្ព័នដឹកនាំ និងគ្រប់គ្រងស្ថាប័ន។

### ៣.១.១ បញ្ហាឆ្លងផ្នែក

បញ្ហាកាត់ផ្តាច់ដ៏សំខាន់នៃសមតុល្យយេនឌ័រត្រូវបានកំណត់នៅក្នុងដំណើរការយុទ្ធសាស្ត្ររបស់ប្រទេស ពិសេសក្នុងវិស័យកសិកម្ម ហើយនឹងត្រូវបានបញ្ចូលទៅក្នុងគ្រប់ទិដ្ឋភាពនៃការងាររបស់ ប.ក.ធ ពេញមួយរយៈពេលធ្វើការ។ យេនឌ័រនឹងភ្ជាប់ជាមួយនឹងគោលដៅយុទ្ធសាស្ត្រទាំងអស់។ បញ្ហាឆ្លងផ្នែក ភ្ជាប់ដោយការអនុវត្តកម្មវិធីទាំងមូលឆ្ពោះទៅសម្រេចបាននូវគោលដៅ និងគោលបំណង។ ស្ត្រីមានជាងពាក់កណ្តាលនៃចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជា ប៉ុន្តែជារឿយៗ

ទទួលរងនូវការរើសអើងនៅក្នុងសង្គម។ យើងជឿថា ដំណើរការអភិវឌ្ឍន៍ប្រកបដោយចីរភាព ទាមទារឱ្យបញ្ហានៃវិសមភាពរវាងបុរស និងស្ត្រីត្រូវបានដោះស្រាយ និងធ្វើសកម្មភាពជាក់លាក់។ មូលហេតុនៃវិសមភាពយេនឌ័រ រួមមាន កង្វះការចែករំលែកអំណាច បទដ្ឋានវប្បធម៌ និងសង្គម ដែលរឹតត្បិតការចូលរួមនៅក្នុងសង្គម ការទម្លាក់តម្លៃបទពិសោធន៍ និងការងារ និងអំពើហិង្សាលើស្ត្រី។ អាទិភាពមួយក្នុងចំណោមអាទិភាពសំខាន់បំផុតគឺ តម្រូវការក្នុងការបញ្ចូលការពិចារណាអំពីយេនឌ័រទៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃការអភិវឌ្ឍន៍កម្មវិធី/គម្រោង។ ស្ត្រី និងបុរសត្រូវបានចូលរួមដោយស្មើភាពគ្នានៅក្នុងវដ្តនៃការអភិវឌ្ឍន៍គម្រោងទាំងមូល។ ប.ក.ធ ជួយសម្រួលដល់ការយល់ដឹង និងការបណ្តុះបណ្តាលជាក់លាក់ ដើម្បីផ្លាស់ប្តូរអាកប្បកិរិយា និងការអនុវត្ត និងជំរុញសហគមន៍កសិកម្មស្វែងរកមតិគាំទ្រ សម្រាប់ការដាក់បញ្ចូលស្ត្រីក្នុងការសម្រេចចិត្ត និងដំណើរការអភិវឌ្ឍន៍។ បញ្ហាយេនឌ័រក៏នឹងត្រូវធ្វើឡើងនៅក្នុង ប.ក.ធ ផងដែរ។

យុវជនជាច្រើនបានបោះបង់ការសិក្សា ហើយត្រូវធ្វើចំណាកស្រុកទៅកាន់តំបន់ទីក្រុង ដើម្បីស្វែងរកការងារដែលមានប្រាក់ខែទាប និងគ្មានសុវត្ថិភាព ឬធ្វើចំណាកស្រុកទៅក្រៅប្រទេស ដែលមនុស្សជាច្រើនធ្វើការដោយខុសច្បាប់ និងកេងប្រវ័ញ្ច។ ដីរបស់ឪពុកម្តាយមិនគ្រប់គ្រាន់ដើម្បីឲ្យពួកគាត់បង្កើតកសិដ្ឋានក្រោយរៀបការទេ។ ផែនការយុទ្ធសាស្ត្រនេះនឹងផ្តោតលើយុវជន (១៨-៣៥ ឆ្នាំ) ជាក្រុមគោលដៅពិសេស ដើម្បីលើកទឹកចិត្តពួកគេឱ្យចូលរួមក្នុងសកម្មភាពកសិកម្ម និងបង្កើតប្រាក់ចំណូល ដើម្បីឱ្យពួកគេរស់នៅក្នុងសហគមន៍ប្រកបដោយសុវត្ថិភាព និងធ្វើឱ្យជីវភាពរស់នៅប្រកបដោយនិរន្តរភាព។

ផែនការយុទ្ធសាស្ត្រក៏ផ្តោតលើជនជាតិដើមភាគតិចដែលពឹងផ្អែកលើព្រៃឈើ និងកសិកម្មប្រពៃណីសម្រាប់ចិញ្ចឹមជីវិត ដែលធ្វើឱ្យពួកគេងាយរងគ្រោះដោយការកាប់ឆ្ការព្រៃឈើ និងការរិចរិលព្រៃឈើ។ ពួកគាត់ខ្វះការយល់ដឹងអំពីសិទ្ធិរបស់ពួកគាត់ (UNDROP) និងរបៀបស្វែងរកមតិគាំទ្ររបស់ពួកគាត់។ ដូចនេះ កម្មវិធី/គម្រោងនៃផែនការយុទ្ធសាស្ត្រនឹងចាត់ពួកគាត់ជាក្រុមគោលដៅដែលងាយរងគ្រោះ ហើយលើកទឹកចិត្តពួកគាត់ឱ្យចូលរួម និងទទួលបានអត្ថប្រយោជន៍ពីសកម្មភាពកម្មវិធីទាំងអស់។

### ៣.២. សូចនាករ និងចំណុចដៅ

ប.ក.ធ

## ៣.៣. អភិក្រម និងបណ្ដាញនៃអន្តរាគមន៍

### ៣.៣.១ អភិក្រមយុទ្ធសាស្ត្រ

**អភិក្រមផ្អែកលើសិទ្ធិ៖** ទីមួយ និងសំខាន់បំផុតគឺពាក់ព័ន្ធនឹងការកសាងការយល់ដឹងអំពីសិទ្ធិមនុស្សនៅគ្រប់កម្រិតទាំងអស់ ទាំងក្នុងចំណោមអ្នកគ្មានអំណាច និងអ្នកមានអំណាច។ អភិក្រមផ្អែកលើសិទ្ធិប្រើប្រាស់ក្របខ័ណ្ឌបទដ្ឋាននៃសេចក្ដីប្រកាស និងអនុសញ្ញារបស់អង្គការសហប្រជាជាតិ គោលដៅអភិវឌ្ឍន៍ចីរភាព រដ្ឋធម្មនុញ្ញជាតិ គោលនយោបាយ និងផែនការអភិវឌ្ឍន៍ដែលគាំទ្រ និងច្បាប់អន្តរជាតិ និងច្បាប់មូលដ្ឋានពាក់ព័ន្ធ ដើម្បីផ្ដល់លទ្ធភាពឱ្យអ្នកមានកាតព្វកិច្ចទទួលខុសត្រូវចំពោះការទទួលខុសត្រូវរបស់ពួកគាត់។ ការពារ និងបំពេញសិទ្ធិរបស់ប្រជាពលរដ្ឋគ្រប់រូប។ ក្នុងពេលជាមួយគ្នានេះ បុគ្គល និងក្រុម (អ្នកកាន់សិទ្ធិ) ត្រូវបានអនុញ្ញាតឱ្យស្វែងរកមតិគាំទ្រ និងទាមទារសិទ្ធិរបស់ពួកគេដើម្បីរស់ដោយសេចក្ដីថ្លៃថ្នូរ។ អភិក្រមនេះកំពុងភ្ជាប់សិទ្ធិមនុស្សទៅនឹងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិស្ថាន។ ដូច្នេះ ការខ្វះស្បៀង និងការបំពុលបរិស្ថានគឺជាការគំរាមកំហែងដោយផ្ទាល់ ឬដោយប្រយោលចំពោះសិទ្ធិរស់រានមានជីវិត និងការចិញ្ចឹមជីវិត។

**អភិក្រមពង្រឹងអំណាច៖** កសាងសមត្ថភាព និងបំណិនរបស់បុគ្គល និងជាក្រុមសមាជិក និងសហគមន៍ ដើម្បីសម្រេចបានលទ្ធផលសម្រាប់ខ្លួនពួកគេ តាមរយៈការផ្ដល់ចំណេះដឹង ជំនាញ និងអាកប្បកិរិយាដែលពង្រីកជម្រើស និងទំនុកចិត្តរបស់ពួកគេ ហើយពួកគេអាចទទួលបានអំណាចក្នុងការគ្រប់គ្រងជីវិតរបស់ពួកគេ និងដើម្បីគ្រប់គ្រងដំណើរការអភិវឌ្ឍរបស់ពួកគេ ដូចជាតម្រូវការ និង ការអភិវឌ្ឍន៍ចក្ខុវិស័យ កសាងផែនការអាជីវកម្ម ការប្រមូលធនធាន ការអនុវត្ត និងត្រួតពិនិត្យ និងវាយតម្លៃផែនការអាជីវកម្ម។ ការពង្រឹងអំណាចគឺជាមធ្យោបាយ ដើម្បីទទួលបានលទ្ធផលនៅក្នុងដំណើរការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

**អភិក្រម ឬវិធីសាស្ត្ររួមបញ្ចូលគ្នា៖** គ្រប់ទិដ្ឋភាព និងធាតុផ្សំនៃកម្មវិធី/គម្រោង ដូចជាសិទ្ធិអំណាចរដ្ឋាភិបាល វិស័យឯកជន និងអ្នកផលិត AC/PGs នឹងត្រូវបានភ្ជាប់គ្នាទៅវិញទៅមកខ្សែច្រវាក់តម្លៃ ដើម្បីឈានទៅសម្រេចផលរួមគ្នា។

**អភិក្រមផ្អែកលើសហគមន៍៖** អនុវត្តការងារអភិវឌ្ឍន៍ ដើម្បីផលប្រយោជន៍សហគមន៍ទាំងមូល។ សន្តិភាព ការផ្សះផ្សា ស្ថិរភាព និងសាមគ្គីភាពត្រូវបានលើកកម្ពស់ ខណៈដែលសមាជិកសហគមន៍ត្រូវបានលើកទឹកចិត្តឱ្យកសាងលើទ្រព្យសម្បត្តិ រចនាសម្ព័ន្ធ និងធនធានផ្ទាល់ខ្លួន ដែលអាចឱ្យពួកគេដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍អាជីវកម្ម និងបំពេញផែនការអភិវឌ្ឍន៍អាជីវកម្មរបស់ពួកគេ។ ការផ្អែកលើសហគមន៍ក៏មានន័យថា បុគ្គលិកកំពុងធ្វើការនៅក្នុងសហគមន៍ ដើម្បី

